# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

> *បងនួនបញ្ជាមកខ្ញុំផ្ទាល់។ ខ្ញុំសូមលើកព្រឹត្តិការណ៍ខ្លះៗ ដើម្បីឲ្យឃើញថា យើងខ្ញុំបានជួបគ្នាមែន។ គាត់ថា អ្នកទោសទាំងប៉ុន្មាន មិត្តកម្ទេចឲ្យអស់ទៅ បញ្ចេញឲ្យអស់។*[1]
>
> **- សាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច**

## ផ្នែកទី១ ៖ ទិដ្ឋភាពទូទៅ

នាសប្តាហ៍នេះ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** និង **ខៀវ សំផន** បានចាប់ផ្តើមសួរដេញដោលសាក្សី **កាំង ហ្គេកអ៊ាវ** ហៅ “**ឌុច**”។

នៅពេលក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** តាំងសំណួរដល់សាក្សី គឺមានការជំទាស់ជាច្រើនបានលើកឡើង និងការមិនឆ្លើយសំណួររបស់ **ឌុច** ពាក់ព័ន្ធនឹងសេចក្តីថ្លែងមុនៗ។ មេធាវី **កាណាវ៉ាស** បានប្រឹងប្រែងបង្ហាញថា សាក្សីរូបនេះមានឋានៈត្រឹមកម្មាភិបាលថ្នាក់មធ្យម ដូច្នេះគាត់មិនអាចយល់ដឹងពីការធ្វើសេចក្តីសម្រេចរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះទេ។ មេធាវី **កាណាវ៉ាស** បានធ្វើការសន្និដ្ឋានថា **ឌុច** បានដឹងព័ត៌មានពីរបបនេះ គឺតាមរយៈការស្រាវជ្រាវរបស់គាត់ក្នុងសំណុំរឿង០០១។ គាត់បានបន្ថែមថា **ឌុច** មិនមានទំនាក់ទំនងជាមួយជនជាប់ចោទ **អៀង សារី** ឬក្រសួងការបរទេសឡើយ។

ចំពោះមេធាវី **អាកទូរ វែកគែន** ដែលជាមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** បានលើកបង្ហាញថា កូនក្តីរបស់ខ្លួនមិនមានជាប់ពាក់ព័ន្ធនឹងចម្លើយសារភាពរបស់ **ឌុច** នោះឡើយ ហើយបន្តថា ចម្លើយរបស់ **ឌុច** ដែលលើកពី **ខៀវ សំផន** គឺគ្រាន់តែជាការឮ ជាការសន្និដ្ឋាន ឬយោងតាមព័ត៌មានដែលទទួលបានពីចម្លើយសារភាពនៅមន្ទីរស-២១ ដែលព័ត៌មាននេះពុំទទួលស្គាល់ជាភស្តុតាងឡើយ។ ត្រង់ចំណុចនេះ គាត់ក៏បានចង្អុលបង្ហាញអំពីភាពមិនស៊ីចង្វាក់គ្នានៅក្នុងចម្លើយរបស់ **ឌុច** ។ នៅពេលក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** បញ្ចប់ការសួរដេញដោលខ្លួនមុនកាលកំណត់ អង្គជំនុំជម្រះបានអនុញ្ញាតផ្តល់វេទិកា

ឲ្យមេធាវីជាតិការពារក្តីឲ្យជនជាប់ចោទ **នួន ជា** (មេធាវី **សុន អរុណ**) បន្តសួរដេញដោល និងធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់ខ្លួន។

នៅចុងបញ្ចប់នៃការផ្តល់សក្ខីកម្មរបស់ **ឌុច** អង្គជំនុំជម្រះ បានប្រកាសអំពីការឈប់សម្រាកចូលរួមប្រារព្ធពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ និងចាប់ផ្តើមដំណើរការវិញនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២។

## ផ្នែកទី២ ៖ សក្ខីកម្មសង្ខេបរបស់ឌុច

បន្ទាប់ពីបញ្ចប់ការសួរដេញដោលដោយសហព្រះរាជអាជ្ញារយៈពេលជាង ៦ថ្ងៃ ដោយដើមបណ្តឹងរដ្ឋប្បវេណី ១ថ្ងៃ និងដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** ជាង ២ថ្ងៃ សប្តាហ៍នេះ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** និង **ខៀវ សំផន** បានចាប់ផ្តើមសួរដេញដោល **ឌុច** ដែលក្រុមនីមួយៗទទួលបានរយៈពេល ១ថ្ងៃ ពេញ។[2] ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** បានប្រើប្រាស់ពេលវេលារបស់ខ្លួនទាំងអស់ ចំណែកឯ ក្រុមមេធាវីការពារក្តីឲ្យជនជាន់ចោទ **ខៀវ សំផន** បានបញ្ចប់ការសួរដេញដោលខ្លួនតិចជាងពេលវេលាផ្តល់ឲ្យ។ ដូច្នេះ អង្គជំនុំជម្រះបានអនុញ្ញាតផ្តល់វេទិកាឲ្យមេធាវី **សុន អរុណ** បន្តការសួរដេញដោលខ្លួន។

### ក. ការសួរដេញដោល ឌុច ដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ អៀង សារី

កាលពីថ្ងៃច័ន្ទ **មេធាវី កាណាវ៉ាស** បានចាប់ផ្តើមសួរដេញដោល **ឌុច** ។ លោកមេធាវីបានព្យាយាមបង្ហាញពីភាពមិនជឿជាក់លើសាក្សីរូបនេះ ដោយថ្លែងថា សក្ខីកម្មរបស់ **ឌុច** គឺបានពីការយល់ដឹងនៅក្នុងសំណុំរឿង០០១ ប៉ុន្តែមិនមែនជាការផ្តល់សក្ខីកម្មដោយការយល់ដឹងផ្ទាល់ខ្លួន និងអំពីព្រឹត្តិការណ៍ជាក់ស្តែងឡើយ តាមរយៈបទពិសោធន៍របស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ **មេធាវី កាណាវ៉ាស** បានព្យាយាមបង្ហាញថា **ឌុច** ពុំមានទំនាក់ទំនងការងារជាមួយ **អៀង សារី** និងមានតួនាទីខ្ពស់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទេ ហើយបន្តថា **ឌុច** មិនបានដឹងការងារក្រៅតែពីវិសាលភាពរបស់**ខ្លួន**នៅមន្ទីរស-២១។ **មេធាវី កាណាវ៉ាស** ក៏បានបង្ហាញថា ហេតុផលដែល **ឌុច** បានដឹងច្រើនអំពីឋានានុក្រម និងដំណើរការធ្វើសេចក្តីសម្រេចរបស់បក្ស គឺដោយសារតែ **ឌុច** បានសិក្សាឯកសារដែលពាក់ព័ន្ធខ្មែរក្រហមនៅក្នុងសំណុំរឿងរបស់ខ្លួន និងព័ត៌មានមួយចំនួនបានពីមេធាវីខ្លួន ក៏ដូចជា អ្នកជំនាញនានា ជាពិសេស អ្នកជំនាញ **រ៉ាអ៊ូល ម៉ាកចេនណា** (Mr. Raoul Jennar) ។[3]

#### *ក.១. តួនាទីរបស់ឌុចនៅមន្ទីរស-២១*

**ឌុច** ទទួលស្គាល់ថា គាត់គ្រាន់តែជាកម្មាភិបាលថ្នាក់មធ្យម និងថ្លែងថា ការយល់ដឹង និងសកម្មភាពរបស់គាត់កម្រិតត្រឹមតំណែងរបស់គាត់។ **ឌុច** បានបន្តថា គាត់បានព្យាយាមអនុវត្តការងារខ្លួនឲ្យល្អប្រសើរបំផុតតាមមាគ៌ាបក្ស និងគោរពតាមការណែនាំពីថ្នាក់លើ រួមមាន **សុន សេន** និង **នួន ជា** ។ នៅពេល **ឌុច** នៅក្នុងមន្ទីរស-២១ ការងារចម្បងៗរបស់គាត់ គឺការទាញយកចម្លើយសារភាពពីអ្នកទោស តាមរយៈបច្ចេកទេសធ្វើទារុណកម្ម ដែលបង្ខំឲ្យអ្នកទោសសារភាពថា ពួកគេមានទំនាក់ទំនងជាមួយនឹង ស៊ី.អាយ.អេ (ទីភ្នាក់ងារស៊ើបការណ៍កណ្តាលរបស់សហរដ្ឋអាមេរិក) កា.ហ្ស៊េ.បេ (គណៈកម្មការសន្តិសុខរដ្ឋរបស់សហភាពសូវៀត) និង យួន (សំដៅលើជនជាតិវៀតណាម)។

យោងតាមសាក្សី ដំបូងឡើយ គាត់បានបញ្ជូនចម្លើយសារភាពរបស់អ្នកទោសឲ្យទៅ **សុន សេន** ។ ក្រោយពី **សុន សេន** ចេញទៅសមរភូមិនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៧ **ឌុច** បានបញ្ជូនចម្លើយសារភាពរបស់មន្ទីរស-២១ ឲ្យទៅ **នួន ជា** ដែលជាអ្នកជំនួសតំណែង **សុន សេន** ។ មេធាវី **កាណាវ៉ាស** បានសួរ **ឌុច** ថាតើគាត់ធ្លាប់ធ្វើទារុណកម្មទៅលើអ្នកទោសឲ្យសរសេរចម្លើយសារភាពរបស់ពួកគេដែរឬទេ "ដើម្បីឲ្យពួកគេនិយាយកុហក"។[4] **ឌុច** បានឆ្លើយត្រង់ចំណុចនេះថា ការនេះមានជាច្រើនករណី នៅពេល **សុន សេន** ឬ **នួន ជា** បានបញ្ជាឲ្យគាត់សួរចម្លើយអ្នកទោសឡើងវិញ ប៉ុន្តែមិនមែនជាការបង្ខំឲ្យពួកគេនិយាយកុហកនោះទេ គឺគ្រាន់តែចង់បានចម្លើយសារភាពឲ្យកាន់តែច្បាស់លាស់។ ករណីរបស់ **កុយ ធួន** មានការបញ្ជាពីថ្នាក់លើឲ្យសរសេរចម្លើយសារភាពដោយខ្លួនគាត់ចំនួនបួនដង។

### *ក.២. ទំនាក់ទំនងជាមួយនឹងមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ*

**ឌុច** បានផ្តល់សក្ខីកម្មថា ក្រៅពីថ្នាក់លើខ្លួន គាត់មិនមានទំនាក់ទំនងជាមួយនឹងសមាជិកជាន់ខ្ពស់ដទៃទៀតឡើយ។ គាត់បានថ្លែងថា ទោះបីជាគាត់ធ្លាប់ចូលរួមក្នុងការរៀបចំពិធីខួបអនុស្សាវរីយ៍ដែលដឹកនាំដោយ **ប៉ុល ពត** និង **នួន ជា** ក៏ដោយ ក៏គាត់មិនធ្លាប់ចូលរួមក្នុងកិច្ចប្រជុំពិភាក្សាលើបញ្ហាធំៗរបស់ប្រទេសជាតិនោះដែរ។ គាត់បានបញ្ជាក់ថា គាត់មិនធ្លាប់មកក្រសួងការបរទេស ឬការិយាល័យ ៨៧០ ហើយក៏មិនធ្លាប់ទទួលការណែនាំពី **អៀង សារី** ទោះដោយផ្ទាល់ ឬតាមរយៈ **សុន សេន** ។

នៅពេលមេធាវី **កាណាវ៉ាស** បន្តចោទសួរ **ឌុច** ចំពោះទំនាក់ទំនងការងាររបស់គាត់ជាមួយនឹង **អៀង សារី** និង **នួន ជា**? **ឌុច** បានថ្លែងថា គាត់មិនបានដឹងការងារច្រើនក្រៅពីការចាត់តាំងដោយគោលការណ៍បក្សឡើយ។ នៅខណៈពេលមេធាវី **កាណាវ៉ាស** បានសួរដេញដោល **ឌុច** ឲ្យបញ្ជាក់ពីព័ត៌មានដែលខ្លួនដឹងដោយមិនយោងគោលការណ៍ចាត់តាំងបក្ស? **ឌុច** បានឆ្លើយថា *"សំណួរនេះធ្វើឲ្យខ្ញុំពិបាកឆ្លើយណាស់។ ខ្ញុំមិនចេះឆ្លើយទេ"។[5]* សាក្សីរូបនេះ ក៏បានឲ្យដឹងពីទំនាក់ទំនងការងារជាក់លាក់រវាង **ប៉ុល ពត** និង **អៀង សារី** ក៏ប៉ុន្តែគាត់ថ្លែងថា ពួកគេទាំងពីរ គឺជាមេធំដែលមានតួនាទីយ៉ាងសំខាន់នៅក្នុងបក្ស។ គាត់បន្ថែមថា "ជាគោលការណ៍ វាមិនដែលមេជាក់ស្តែង មិនគោរពមេធំទេ"។[6]

### *ក.៣. ការភ័យខ្លាច និងការសម្ងាត់*

**ឌុច** បានថ្លែងថា គាត់បានដឹងពីកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ក្នុងការសម្រេចចាប់ខ្លួន **សួស នៅ** ហៅ **ឈូក** តាមរយៈ **សុន សេន** ។ គាត់ក៏បានឲ្យដឹងពីការសាកសួរ **ប៉ង់** ពីកិច្ចប្រជុំរបស់គណៈមជ្ឈិមក្នុងករណីចាប់ **ជូ ជេត** ហៅ **ស៊ី** ព្រោះគាត់បានដឹងរឿងនោះ។ នៅពេលដែលមេធាវី **កាណាវ៉ាស** បានចោទសួរសាក្សី ថាតើគាត់មានការភ័យខ្លាចដែរឬទេ នៅពេលធ្វើការនៅមន្ទីរស-២១? បន្ទាប់មក **ឌុច** បានបញ្ជាក់ថា ចាប់តាំងពីឆ្នាំ១៩៧៦ គាត់មានការប្រុងប្រយ័ត្នខ្ពស់នៅក្នុងការមិនឲ្យមានការចាប់ខ្លួនគាត់ ដោយថ្លែងថា "ការងារគេ គេដឹង ការងារយើង យើងដឹង"។[7] ត្រង់ចំណុចនេះ មេធាវី **កាណាវ៉ាស** បានចង្អុលបង្ហាញថា **ឌុច** បានសាកសួរ **ប៉ង់** ពីព័ត៌មានសំខាន់ៗ ដែលគាត់ (**ឌុច**) មិនមានសិទ្ធិដឹងរឿងនេះទេ។ មេធាវី **កាណាវ៉ាស** បានបន្តការសួរដេញដោល ថាតើ **ឌុច** មិនភ័យខ្លាចថា **ប៉ង់** អាចនឹងចោទគាត់ពីបទព្យាយាមយកព័ត៌មាន។ **ឌុច** បានឆ្លើយថា "រឿងនេះ វាស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ខ្ញុំ"[8] និងបានបញ្ជាក់ថា គាត់មិនមានចេតនាព្យាយាមកម្ទេចគណៈអចិន្ត្រៃយ៍ ដូច្នេះ ការសាកសួរដូចនេះមិនមែនជាបញ្ហាទេ។ នៅថ្ងៃរសៀល មេធាវី

**កាណាវ៉ាស** បានបន្តការសួរដេញដោល **ឌុច** អំពីកាលៈទេសៈនៃការចាប់ខ្លួន ***វ៉ន វ៉េត*** ។ **ឌុច** បានរម្លឹកថា នៅពេល ***វ៉ន វ៉េត*** ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១ គាត់ពិតជាបានជួប ***វ៉ន វ៉េត*** និងបានសុំអភ័យទោសគាត់។ **ឌុច** បានបន្តជជែកជាមួយ ***វ៉ន វ៉េត*** ពីមូលហេតុដែលនាំឲ្យមានការចាប់ខ្លួនគាត់ ព្រមទាំងសួរអំពីអត្តចរិតរបស់ **ប៉ុល ពត** ថាតើគាត់ជាមនុស្សប្រភេទណា ដើម្បីឲ្យគាត់អាចការពារខ្លួន និងជៀសវាងករណីនេះ។

### *ក.៤. ការបញ្ជាក់ចម្លើយមុនៗ ទាំងចម្លើយជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់*

**ឌុច** បានបញ្ជាក់ថា មេធាវីរបស់គាត់មិនបានផ្ដល់ឯកសារណាមួយដល់គាត់ជាទុន មុនពេលជួបជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងករណីសំណុំរឿង០០១ទេ។ ទោះបីជាយ៉ាងណា ឯកសារទាំងនោះត្រូវបានផ្ដល់ដល់គាត់នៅពេលសវនាការរបស់គាត់ចាប់ផ្ដើម។ **ឌុច** បានពិភាក្សាអំពីទង់ជ្ញាយប្រាំរបស់សាធារណរដ្ឋប្រជាមានិតចិន ជាមួយនឹងលោក **រ៉ាអ៊ូល ចេនណា (Mr. Raoul Jennar)** ។ តាមឲ្យដឹង លោក **ចេនណា** ដំបូងឡើយ គឺស្ថិតនៅក្នុងក្រុមមេធាវីការពារក្ដីរបស់ **ឌុច** និងក្រោយមកបានឡើងមកផ្ដល់សក្ខីកម្មជាសាក្សីជំនាញនៅក្នុងសំណុំរឿង០០១។ **ឌុច** បានបន្ថែមថា លោក **ចេនណា** បានផ្ដល់សៀវភៅនិយាយពីរបបកុម្មុយនីស្ដដល់គាត់។

បន្ទាប់មក មេធាវី **កាណាវ៉ាស** បានលើកបង្ហាញឯកសារមួយដែលមានចំណងជើងថា ***មេរៀនដកពិសោធន៍*** របស់ចាស់ទុំជំនាន់មុន ដែលសៀវភៅនេះចងក្រងដោយ **ឌុច** នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១២។ ដើម្បីទទួលប្រភពព័ត៌មានពីការរៀបចំសៀវភៅនេះ មេធាវី **កាណាវ៉ាស** បានសួរដេញដោល **ឌុច** ថាតើឯកសារទាំងនោះបានមកពីប្រភពណា "ដោយការឮ ការស្រាវជ្រាវ ការវិភាគ និងការបូកសរុបផ្ទាល់ខ្លួន"?[9] **ឌុច** បានបញ្ជាក់ថា ឯកសារទាំងនោះបានមកពី "ការដែលគាត់បានជួបប្រទះ បានដឹងឮ និងការស្រាវជ្រាវ"។[10]

មេធាវី **កាណាវ៉ាស** បានបន្តដកស្រង់ព័ត៌មានពីប្រតិចារឹកនៃកិច្ចដំណើរការសវនាការនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ដោយ **ឌុច** បានលើកឡើងថា ៖

> *ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើយើងចង់ឲ្យខ្ញុំនិយាយតែអ្វីដែលខ្ញុំដឹងនៅពេលនោះ ខ្ញុំខ្លាចតែថា ខ្ញុំគ្មានអ្វីនឹងឆ្លើយជូនជាតិប្រជាជន ព្រោះថា ការយល់ដឹងរបស់ខ្ញុំនៅត្រឹមតែស-២១ ។*[11]

**ឌុច** បានអះអាងថា ចម្លើយខាងលើរបស់គាត់ សុទ្ធសឹងជាព័ត៌មានពិត។ បន្ថែមលើនេះ គាត់បានបញ្ជាក់ពីភាពត្រឹមត្រូវនៃកិច្ចសម្ភាសន៍នៅការិយាល័យសហចៅក្រមស៊ើបអង្កេតថា ៖

> *ជាដំបូង ខ្ញុំសូមបញ្ជាក់ថា នៅក្នុងពេលនេះ ខ្ញុំមានការយល់ដឹងច្រើនជាងនៅខែសីហា ឬខែធ្នូ កន្លងទៅ។ តាមពិតទៅ ពេលដែលខ្ញុំបានដឹងបន្តិចម្តងៗពីសំណុំរឿង ខ្ញុំយល់កាន់តែច្បាស់ពីរចនាសម្ព័ន្ធនៃរបបនោះ។*[12]

> *ខ្លួនខ្ញុំផ្ទាល់មិនដឹងអំពីការងាររបស់អ្នកដទៃនោះឡើយ។ តាមរយៈនេះ គឺថា យើងមិនអាចទាញសេចក្ដីសន្និដ្ឋានថា របបនោះជារបបឧក្រិដ្ឋ ដោយគ្រាន់តែដឹងថា ឧក្រិដ្ឋកម្មនោះត្រូវបានប្រព្រឹត្តនៅស-២១ ឡើយ។*[13]

*មូលហេតុដែលខ្ញុំរង់ចាំឲ្យមានការអនុវត្តតាមសំណូមពររបស់យើងខ្ញុំ ពីព្រោះសំណូមពរនោះ ទាមទារសុំច្បាប់ថតចម្លងនៃឯកសារភស្តុតាង យកមកអាន ពិចារណា និងរម្លឹកឡើងវិញ។ --- ជាសរុប ខ្ញុំត្រូវការសេក្តីភាពគ្រប់បែបយ៉ាង ដើម្បីរួមចំណែកបំភ្លឺជូនតុលាការនូវឧក្រិដ្ឋកម្មដែលកើតឡើងនៅមន្ទីរស-២១។*[14]

ផ្អែកតាម **ឌុច** នៅដំណាក់កាលស៊ើបអង្កេតនៅក្នុងសំណុំរឿង០០១ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានផ្តល់ឲ្យគាត់នូវសំណួរជាច្រើន ហើយគាត់មានពេលជាច្រើនសប្តាហ៍ក្នុងការឆ្លើយតបសំណួរទាំងនោះ។ គាត់បានបញ្ជាក់ថា គាត់បានផ្តល់ចម្លើយបឋមរបស់គាត់ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា “នៅស-២១ ខ្ញុំខំគេចពីការងារជាអតិបរមា ទទួលតែការងារណាដែលចៀសមិនរួច ម្ល៉ោះហើយខ្ញុំមិនដែលក្តាប់អីបានជាក់ស្តែងទេ”។[15] **ឌុច** បានបន្ថែមថា គាត់ធ្លាប់បានអានសៀវភៅរបស់លោក **និក ឌុនលប** ដែលមានចំណងជើងថា ***ពេជ្ឈឃាដបាត់ខ្លួន*** និងសៀវភៅរបស់លោក **ដេវីដ ឆេនដ៍ល័រ** ដែលមានចំណងជើងថា ***សម្លេងពីមន្ទីរស-២១*** ដែលលើកឡើងពី *ប្រវត្តិពន្ធនាគារសម្ងាត់របស់* ***ប៉ុល ពត*** ។ **ឌុច** ក៏បានផ្តល់យោបល់របស់គាត់ចំពោះសៀវភៅទាំងនេះដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

**ឌុច** បានគូសបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានមនុស្សឈរជួរមុខដើម្បីលាក់បំបាំងមនុស្សសំខាន់ៗ។ គាត់បន្ថែមថា នៅក្នុងចំណោមសមាជិកទាំងប្រាំពីររូបនៃគណៈអចិន្ត្រៃយ៍ មានបីរូប គឺជាអ្នកទទួលខុសត្រូវផ្នែកសន្តិសុខ រួមមាន៖ **ប៉ុល ពត, នួន ជា** និង **សុន សេន**។

### *ក.៥. ការបោសសម្អាតនៅក្រសួងការបរទេស*

មេធាវី **កាណាវ៉ាស** បានសួរដេញដោល **ឌុច** “តាមហេតុការណ៍ជាក់ស្តែង”[16] ថាតើ **ឌុច** បានដឹងពីរបៀបនៃការចាប់ខ្លួនមនុស្សនៅក្រសួងការបរទេសដែរឬទេ។ ជាងនេះទៀត មេធាវី **កាណាវ៉ាស** បានសួរ **ឌុច** ថាតើគាត់អាចចង្អុលបង្ហាញពីភស្តុតាងដែលបង្ហាញថា **អៀង សារី** ទទួលបានព័ត៌មាន ឬបានជួបពិភាក្សា មុននឹងឈានដល់ការចាប់ខ្លួនមនុស្សនៅក្រសួរការបរទេស និងបញ្ជូនទៅមន្ទីរស-២១ដែរឬទេ។ ជាការឆ្លើយតប **ឌុច** បានចាប់ផ្តើមពន្យល់ពី “គោលការណ៍” នៃការធ្វើសេចក្តីសម្រេចចិត្ត។ គាត់បានបន្តថា ប្រសិនបើ **អៀង សារី** មិនបានចូលរួមក្នុងកិច្ចប្រជុំរបស់គណៈមជ្ឈិម **ប៉ុល ពត** នឹងធ្វើសេចក្តីសម្រេច បន្ទាប់មកសេចក្តីសម្រេចនោះនឹងបញ្ជូនទៅ **អៀង សារី** ។ សាក្សីក៏បានពន្យល់ពីឯកសារដែលមានចំណារ **សុន សេន** និង **ប៉ុល ពត** ដោយការរៀបរាប់នេះ គឺចង់បង្ហាញថា **សុន សេន** បានស្នើសុំការណែនាំពី **ប៉ុល ពត** ។

បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែង នៅទីបញ្ចប់ សាក្សីបានឆ្លើយតបទៅតាមសំណួររបស់មេធាវី **កាណាវ៉ាស** ដែលទទួលស្គាល់ថា គាត់មិនធ្លាប់បានទទួលការណែនាំពី **អៀង សារី** ក្នុងការសួរយកព័ត៌មានពីបុគ្គលណាមួយឡើយ។ សាក្សីក៏បន្តថា “តាមការអនុវត្ត”[17] គាត់មិនបានដឹងពីទំនាក់ទំនងរវាង **អៀង សារី** ជាមួយនឹង **នួន ជា** ឬ **សុន សេន** អំពីការចាប់ខ្លួនមនុស្សនៅក្រសួងការបរទេស។

### *ក.៦. តួនាទីរបស់ អៀង សារី ក្នុងការធានាសុវត្ថិភាពក្មេងៗ ដែលឪពុកម្ដាយរបស់គេត្រូវបានចាប់ខ្លួន*

**ឌុច** បានផ្ដល់សក្ខីកម្មថា **អៀង សារី** "បានរក្សាទុក" កូនរបស់ **តូច ខាំឌឿន** និងកូនសមមិត្ត **ណាត** ព្រមទាំងកូនៗរបស់អ្នកដែលត្រូវចាប់ខ្លួនដទៃទៀត។ ក្មេងៗទាំងនោះត្រូវរក្សាឲ្យរស់រានមានជីវិត។ ទោះបីជាយ៉ាងណា **ឌុច** មិនបានពន្យល់ពីមូលហេតុដែល **អៀង សារី** សម្រេចរក្សាក្មេងៗទាំងនោះឡើយ។ ផ្ទុយទៅវិញ គាត់បញ្ជាក់ថា គាត់ហាក់មានការខ្មាសខ្លួនឯង ព្រោះគាត់មិនហ៊ានស្នើ *អង្គការ* ឲ្យបង្កើតមជ្ឈមណ្ឌលកុមារកំព្រានោះទេ ដូច្នេះ គាត់បានកោតសរសើរ **អៀង សារី** ដែលអាចធ្វើរឿងនេះបាន។ **ឌុច** បានទទួលស្គាល់ថា គាត់មិនបានដឹងពីព្រឹត្តិការណ៍នេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែគាត់បានដឹងឮពីព័ត៌មាននេះនៅឆ្នាំ១៩៩០។ នៅពេលមានសំណួរ ថាតើគាត់ទទួលបានព័ត៌មានដែលថា **អៀង សារី** មានជាប់ពាក់ព័ន្ធនឹងការចាប់ខ្លួនឪពុកម្ដាយរបស់ក្មេងៗទាំងនោះ? **ឌុច** បានឆ្លើយថា **"តាមគោលការណ៍" អៀង សារី** ត្រូវតែដឹងពីបញ្ហានេះ។ មេធាវី **កាណាវ៉ាស** បានសង្កត់ធ្ងន់ទៅលើចំណុចនេះ និងព្យាយាមគ្រប់គ្រង **ឌុច** ដើម្បីឲ្យគាត់ផ្ដល់ចម្លើយទៅតាមសំណួរដែលខ្លួនចង់បាន។ **ឌុច** បានទទួលស្គាល់ថា គាត់មិនមានភស្តុតាងបញ្ជាក់ពី **អៀង សារី** ទេ។ ប៉ុន្តែ សាក្សីនៅរក្សាជំហរថា ជាគោលការណ៍ **អៀង សារី** ត្រូវតែដឹងពីការចាប់ខ្លួនមនុស្សទាំងនោះ ព្រោះថា **អៀង សារី** បានចូលរួមកិច្ចប្រជុំដែលសម្រេចការចាប់ខ្លួនមនុស្ស ឬក៏មានការរាយការណ៍ដល់ **អៀង សារី** បន្ទាប់ពីការចាប់ខ្លួន។

## ខ. ការសួរដេញដោល ឌុច ដោយក្រុមមេធាវីការពារក្ដីឲ្យជនជាប់ចោទ ខៀវ សំផន

មេធាវី **អាកទូរ វ៉េកគែន** ដែលជាមេធាវីអន្តរជាតិការពារក្ដីឲ្យជនជាប់ចោទ **ខៀវ សំផន** បានព្យាយាមលើកបង្ហាញថា ការអះអាងរបស់ **ឌុច** អំពីតួនាទីកូនក្ដីខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺយោងតែតាមការសន្មត ឬចម្លើយដែលបានមកពីការប្រើទារុណកម្មដែលពុំទទួលស្គាល់ជាភស្តុតាង។ ជាងនេះទៀត មេធាវី **វ៉េកគែន** បានតតាំងនឹងភាពគួរឲ្យជឿជាក់របស់ **ឌុច** ព្រមទាំងដេញដោល **ឌុច** ពាក់ព័ន្ធនឹងចម្លើយដែលមិនស៊ីចង្វាក់គ្នា។

### *ខ.១. ទំនាក់ទំនងជាមួយ ខៀវ សំផន*

យោងតាម **ឌុច** គាត់បានជួបជនជាប់ចោទ **ខៀវ សំផន** ម្ដងគត់ពីចម្ងាយនៅក្នុងពិធីបុណ្យខួប ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ និងទទួលស្គាល់ថា តាមគោលការណ៍បក្ស គាត់មិនមានសិទ្ធិជួប **ខៀវ សំផន** នោះទេ ពីព្រោះថា នាពេលនោះ ពួកគេអាចជួប និងរាយការណ៍ជូនតែមេផ្ទាល់របស់ខ្លួន។ **ខៀវ សំផន** មិនមែនជាមេផ្ទាល់របស់គាត់នោះទេ ដូច្នេះ គាត់មិនត្រូវបានអនុញ្ញាតឲ្យជួបឡើយ។ គាត់បានបន្ថែមថា **សុន សេន** មិនធ្លាប់និយាយ ឬរម្លឹកពីជនជាប់ចោទ **ខៀវ សំផន** ចំពោះមុខគាត់ដែរ ដោយសារតែពួកគេពុំមានទំនាក់ទំនងការងារជាមួយគ្នា។ មេធាវី **វ៉េកគែន** បានបន្តសួរបញ្ជាក់ **ឌុច** ថាតើ **ខៀវ សំផន** ធ្លាប់បានអានចម្លើយសារភាពនៅមន្ទីរស-២១ដែរឬទេ។ សាក្សីបានឆ្លើយតបថា គាត់មិនបានដឹង ថាតើមេរបស់គាត់យកចម្លើយសារភាពរបស់មន្ទីរស-២១ ទៅប្រើប្រាស់សម្រាប់គោលបំណងអ្វីនោះទេ ក៏ប៉ុន្តែបានដឹងថា គឺមិនមែនឲ្យ **ខៀវ សំផន** ទេ។ គ្មានបុគ្គលណាម្នាក់ បានអានចម្លើយសារភាពទាំងនោះមុន **សុន សេន** ដែលជាមេរបស់គាត់ឡើយ។

### ខ.២. ការពន្យល់ពីចម្លើយដែលមិនស៊ីចង្វាក់គ្នា

**ឌុច** បានផ្តល់សក្ខីកម្មថា **សុន សេន** បាន "អនុញ្ញាត" ឲ្យអ្នកទោសមន្ទីរស-២១ឆ្លើយដាក់ **ប៉ង់** ដែលនាពេលនោះ **ប៉ង់** ត្រូវបានគេដៅរួចជាស្រេច។[18] ចំណុចនេះបានធ្វើឲ្យមេធាវី **វែកគែន** ឆក់ឱកាសសួរបញ្ជាក់ថាតើ **ឌុច** មានការប្រុងប្រយ័ត្នខ្លួនដែរឬទេ នៅពេលសាកសួរ **ប៉ង់** ពីប្រតិបត្តិការរបស់គណៈមជ្ឈិម? ព្រោះគាត់បានអះអាងនៅពេលផ្តល់សក្ខីកម្មឲ្យក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** ដែលថា **ប៉ង់** កំពុងស្ថិតក្រោមការឃ្លាំមើល។ **ឌុច** បានពន្យល់ថា មនុស្សដែល **ប៉ុល ពត** និង **នួន ជា** មិនជឿទុកចិត្ត គឺមិនបានដឹងពីការឆ្លើយដាក់ ឬការលែងទុកចិត្តពីមេខ្លួនឡើយ។ ដូច្នេះ **ប៉ង់** ប្រហែលជាមិនបានដឹងពីបញ្ហានេះ និងនៅតែធ្វើការងារដូចសព្វដង។ **ឌុច** មានជំនឿយ៉ាងមុតមាំថា **ប៉ង់** មិនអាចឆ្លើយដាក់ខ្លួនឡើយ ព្រោះថា "តើបុគ្គលិក ស-២១ ដែលសួរចម្លើយ **ប៉ង់** គេអនុញ្ញាតឲ្យ **ប៉ង់** ឆ្លើយដាក់ខ្ញុំឬទេ? ទីពីរ ប្រសិនបើ **ប៉ង់** ហ៊ានឆ្លើយដាក់ ថាតើថ្នាក់លើជឿគាត់ឬទេ?"[19] **ឌុច** បញ្ជាក់សាជាថ្មីថា គាត់មិនបារម្ភពីការឆ្លើយដាក់របស់ **ប៉ង់** នោះទេ។ ជាបន្ទាប់ មេធាវី **វែកគែន** បានធ្វើការតតាំងនឹងចម្លើយមុនៗរបស់ **ឌុច** ដែលបញ្ជាក់ថា គាត់មានការភ័យខ្លាច។ **ឌុច** បានពន្យល់ថា មានព្រឹត្តិការណ៍ពីរទៅបីដងដែលធ្វើឲ្យគាត់មានការភ័យខ្លាច។ គាត់បានថ្លែងថា គាត់មិនមានការភ័យខ្លាចចំពោះការសន្ទនាជាមួយនឹង **ប៉ង់** ទេ ដោយថា ៖ គាត់បានរាយការណ៍ដល់មេរបស់គាត់។

កាលពីមុន **ឌុច** បានអះអាងថា គាត់មិនបានសួរចម្លើយ និងមិនបានទៅមន្ទីរស-២១ឡើយ នៅពេល **ប៉ង់** ចាប់បញ្ជូនទៅទីនោះ។[20] នៅក្នុងកំណត់ហេតុយកចម្លើយរបស់តុលាការយោធា **ឌុច** បានរម្លឹកថា "ជួនកាលខ្ញុំបានសន្ទនាជាមួយអ្នកដែលត្រូវបានសួរចម្លើយចប់រួចរាល់ ដូចជា ឈ្មោះ **តុក ពួន** និង **ឈឹម សំអោក** ហៅ **ប៉ង់**"។[21] គាត់បានបន្តថា គាត់ក៏បានជួបសន្ទនាជាមួយ **ជូ ជេត** និង **វន វ៉េត** បន្ទាប់ពីពួកគេត្រូវបានសួរចម្លើយចប់ផងដែរ។ មេធាវី **វែកគែន** និងលោកចៅក្រម **ហ្សង់ម៉ាក ឡាវែន៍** (Judge Jean-Marc Lavergne) បានតតាំងសាក្សីពីភាពខុសគ្នាដែលមាននៅក្នុងកំណត់ហេតុយកចម្លើយរបស់គាត់។ **ឌុច** បានពន្យល់ថា ការលេចចេញពីភាពមិនស៊ីចង្វាក់គ្នានៅក្នុងចម្លើយរបស់ខ្លួន ពីព្រោះកំណត់ហេតុរបស់តុលាការយោធា បានបូកសរុបចម្លើយរបស់គាត់។ កំណត់ហេតុយកចម្លើយគាត់ បានពិពណ៌នាសំដៅទៅលើបុគ្គលបួនរូប ក៏ប៉ុន្តែដោយសារការប្រើ "កិរិយាសព្ទតែមួយ គុណនាមតែមួយ គុណកិរិយាពិសេសតែមួយ" បានធ្វើឲ្យមានភាពភាន់ច្រឡំ។[22] គាត់បានជួប **តួច ភឿន** និង **ជូ ជេត** បន្ទាប់ពីពួកគេត្រូវបានសួរចម្លើយរួច និងបានជួប **វន វ៉េត** មុនពេលគាត់ត្រូវបានយកទៅសួរចម្លើយ ព្រមទាំងបានជួប **ប៉ង់** មុនពេលគាត់ត្រូវចាប់ខ្លួន។

### ខ.៣. ប្រភពនៃការយល់ដឹងអំពីតួនាទី ខៀវ សំផន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

**ឌុច** បានថ្លែងថា **ខៀវ សំផន** បានគ្រប់គ្រងយ៉ាងតិចណាស់អង្គភាពមួយ ដែលគេស្គាល់ថាជារោងចក្រអគ្គិសនីចាក់អង្រែ។ គាត់បានពន្យល់ពីហេតុផលនេះថា **យក់ ជួង** ហៅ **ជន** ដែលជាប្រធានរោងចក្រអគ្គិសនីចាក់អង្រែ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរស-២១។ **យក់ ជួង** បានសារភាពថា **ខៀវ សំផន** បានបង្រៀនគាត់ឲ្យធ្វើជាភ្នាក់ងារ សេ.អ៊ី.អា។ សាក្សីបានប្រាប់ព័ត៌មាននេះទៅ **នួន ជា** ប៉ុន្តែ **នួន ជា** មិនបានចាត់សកម្មភាពអ្វីឡើយ។[23] ទោះបីជាយ៉ាងណា **ឌុច** បានយល់ដឹងពីភាពស្ងប់ស្ងៀមរបស់ **នួន ជា** ដោយថា បក្សកុម្មុយនីស្តកម្ពុជាបានតែងតាំង **ខៀវ សំផន** ឲ្យគ្រប់គ្រងលើរោងចក្រអគ្គិសនីនោះ។

សាក្សីបានបន្តសក្ខីកម្មថា នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គាត់បានចូលរួមកិច្ចប្រជុំមួយនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រោមអធិបតីភាពរបស់ជនជាប់ចោទ **ខៀវ សំផន** និងសមមិត្ត **វឿន** ។ គាត់បានដឹងថា សមមិត្ត **វឿន** គឺជាប្រធានឃ្លាំងរដ្ឋ ដូច្នេះ គាត់ធ្វើការសន្និដ្ឋានថា **ខៀវ សំផន** ត្រូវតែជាអ្នកត្រួតត្រាឃ្លាំងរដ្ឋ។ ដើម្បីឲ្យការសន្និដ្ឋានរបស់គាត់កាន់តែមានភាពជឿជាក់ **ឌុច** បានបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អង្គប្រជុំស្ថិតក្រោមអធិបតីភាពរបស់បុគ្គលណា បុគ្គលនោះគឺជាមេគេ។ មេធាវី **វែកគែន** បានបន្តចោទសួរ ថាតើពួកគេមានពិភាក្សាពីរឿងឃ្លាំងរដ្ឋនៅក្នុងកិច្ចប្រជុំដែរឬទេ។ **ឌុច** បានឆ្លើយតបថា នៅក្នុងកិច្ចប្រជុំនោះ ពួកគេពិភាក្សាតែរឿងវៀតណាមវាយចូលប៉ុណ្ណោះ។[24]

ជាងនេះទៀត **ឌុច** បានទម្លាយប្រាប់ថា គាត់បានជឿ **ប៉ង់** នៅពេលដែល **ប៉ង់** បានប្រាប់គាត់ថា **ខៀវ សំផន** បានចុះហត្ថលេខាលើលិខិតដើរផ្លូវរបស់គាត់ដោយប្រើហស្សនាមថា "ខាង"។ **ឌុច** បានពន្យល់ថា ជាទូទៅ **សុន សេន** ដែលជាមេរបស់គាត់ គឺជាអ្នកចុះហត្ថលេខាលើលិខិតដើរផ្លូវនេះ។ ក៏ប៉ុន្តែ នៅពេល **នួន ជា** ចូលជំនួសកន្លែង **សុន សេន** គាត់បានសបញ្ជាក់ថា **នួន ជា** មានតួនាទីខ្ពស់ ដូច្នេះ មិនមានភារកិច្ចចុះហត្ថលេខាលើលិខិតដើរផ្លូវឡើយ។ ហេតុនេះទើប **ឌុច** ធ្វើការសន្និដ្ឋានថា មានតែ **ខៀវ សំផន** ទេដែលជាអ្នកចុះហត្ថលេខាលើលិខិតដើរផ្លូវរបស់គាត់ជំនួសឲ្យ **នួន ជា** ។ **ឌុច** បានរម្លឹកថា គាត់បានឃើញសំណេរដៃរបស់ **ខៀវ សំផន** ដូច្នេះគាត់អាចចំណាំបាន។

## គ. ការសួរដេញដោល ឌុច ដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ នួន ជា

បន្ទាប់ពីក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** បានបញ្ចប់ការតាំងសំណួរដល់សាក្សី អង្គជំនុំជម្រះសាលាដំបូង បានអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** ប្រើប្រាស់ពេលដែលនៅសល់បន្តការសួរដេញដោលសាក្សី និងធ្វើការបញ្ជាក់ទៅលើចំណុចដែលមិនច្បាស់លាស់។ លោកមេធាវី **សុន អរុណ** បានចោទសួរ **ឌុច** ចំពោះឯកសារដែល **ឌុច** បានឆ្លើយថា **នួន ជា** មានជាប់ពាក់ព័ន្ធនឹងមន្ទីរស-២១ និងសួរបញ្ជាក់ពីរបៀបដែលមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើសេចក្តីសម្រេច។

### *គ.១. លិខិតចេញពី នួន ជា*

មេធាវី **សុន អរុណ** បានត្រួតពិនិត្យចម្លើយរបស់ **ឌុច** នៅពេលឆ្លើយតបនឹងមេធាវី **វែកគែន** ដែលថា **នួន ជា** បានផ្ញើលិខិតមួយមកឲ្យគាត់ ហើយណែនាំគាត់ឲ្យធ្វើការងារជាមួយនឹង **វន វ៉េត** ។[25] នៅពេលមានសំណួរសួរពីទីតាំងដែលទុកលិខិតនោះ? **ឌុច** បានថ្លែងថា គាត់មិនបានរក្សាទុកលិខិតនោះទេ ប៉ុន្តែលិខិតផ្សេងទៀតរបស់ **នួន ជា** គឺបានរក្សាទុកនៅមន្ទីរស-២១ រហូតដល់វៀតណាមចូល។ **ឌុច** បានពន្យល់ដោយភាពជឿជាក់ថា ការណែនាំរបស់ **នួន ជា** គឺបានពីបញ្ជា **ប៉ុល ពត** ។ **ប៉ុល ពត** ជាអ្នកសម្រេច ចំណែកឯ **នួន ជា** ជាអ្នកអនុវត្តន៍ និងឃ្លាំមើលសេចក្តីសម្រេចទាំងនោះ។

### *គ.២. ការធ្វើសេចក្តីសម្រេចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

មេធាវី **សុន អរុណ** បានគូសបញ្ជាក់លើភាពមិនគួរឲ្យជឿជាក់ ដែល **ឌុច** បានដឹងព័ត៌មានដ៏ច្រើន និងបានសន្និដ្ឋានថា **ឌុច** គ្រាន់តែជាលេខាមន្ទីរស-២១។ ជាការឆ្លើយតប **ឌុច** បានពន្យល់ថា គាត់បានចាប់ផ្តើម

រៀនពីមាគ៌ាបក្ស និងលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជាតាំងពីឆ្នាំ១៩៦៧ មកម្ល៉េះ។ គាត់ក៏ធ្លាប់បានអានពីប្រវត្តិបដិវត្តន៍របស់ប្រទេសចិន។ ផ្អែកតាមមាគ៌ាបក្សកុម្មុយនីស្ត **ឌុច** បានឲ្យដឹងថា អ្នកក្រោមត្រូវស្តាប់តាមបង្គាប់ថ្នាក់លើ។ អនុលេខាត្រូវស្តាប់តាមលេខា។ សាក្សីបន្តថា តាមលក្ខន្តិកៈបក្ស ចំណុចនេះជាការបង្ហាញពីការគោរពបក្ស។ នៅពេលមកកាន់តំណែងនៅ ម-១៣ គាត់ត្រូវបានគេប្រាប់ឲ្យគោរពតាមសេចក្តីសម្រេចរបស់មជ្ឈិមបក្ស។

**ឌុច** បានបញ្ជាក់បន្ថែមថា **នួន ជា** អាចធ្វើសេចក្តីសម្រេចនៅពេលដែល **ប៉ុល ពត** អវត្តមាន។ គាត់បានពន្យល់ថា នៅពេលដែល **ប៉ុល ពត** មានជម្ងឺ គាត់បានរាយការណ៍អំពីចម្លើយសារភាពរបស់លោក **គង់ គៀន** ទៅ **សុន សេន** បន្ទាប់មក "**សុន សេន** បានធ្វើចំណារជូន **បងនួន** ផ្ទាល់។ ជាក់ស្តែងដែល **បងប៉ុល** មិននៅ **បងនួន** ជាអ្នកសម្រេច"។[26] **ឌុច** បានបន្តថា **នួន ជា** បានបញ្ជាមកគាត់ដោយផ្ទាល់ក្នុងការកម្ទេចអ្នកទោសនៅមន្ទីរស-២១ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩។ **ឌុច** រម្លឹកថា នៅគ្រានោះ **នួន ជា** បាននិយាយថា "អ្នកទោសទាំងប៉ុន្មាន មិត្តកម្ទេចឲ្យអស់ទៅ បញ្ចេញឲ្យអស់"។[27] យោងតាមបញ្ជា **ឌុច** បានកម្ទេចអ្នកទោសដែលនៅសេសសល់ទាំងអស់ នៅថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩។

ផ្អែកតាមសាក្សី នៅពេលសមមិត្ត **លីន** និង **ណាត** បានសុំគាត់ទៅចូលរួមកិច្ចប្រជុំ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ គាត់មានការភ្ញាក់ផ្អើលជាខ្លាំង ដែលបានដឹងថា **នួន ជា** បានធ្វើជាអធិបតីភាពជំនួស **សុន សេន** ។ គាត់បានបន្តថា ពុំមានឯកសារផ្លូវការណាមួយស្តីពីការផ្ទេរសិទ្ធិអំណាច ឬចាត់តាំង **នួន ជា** ឲ្យជំនួសតំណែងរបស់ **សុន សេន** ឡើយ។ ក៏ប៉ុន្តែ **ឌុច** បានថ្លែងថា **នួន ជា** បានប្រាប់គាត់ថា **នួន ជា** បានមកដឹកនាំជំនួសកន្លែង **សុន សេន** ។

## គ. ឥរិយាបថ និងភាពគួរឲ្យជឿជាក់

ភាពគួរឲ្យជឿជាក់លើសក្ខីកម្មរបស់ **ឌុច** នៅតែមានលក្ខណៈខ្ពស់។ គាត់មិនបានបដិសេធមិនឆ្លើយសំណួរ ហើយមិនបានរារែកក្នុងការស្នើសុំមើលឯកសារមុននឹងឆ្លើយសំណួរ។ ជាងនេះទៀត នៅពេលដែលមានការលើកបង្ហាញពីកំណត់ហេតុយកចម្លើយមុនៗរបស់គាត់ គាត់តែងតែធ្វើការអះអាង ឬផ្តល់ការពន្យល់ប្រសិនបើសក្ខីកម្មនាពេលបច្ចុប្បន្នរបស់គាត់មិនស្របនឹងចម្លើយមុន ដែលគាត់បានផ្តល់ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត។

ទោះបីជាយ៉ាងណា **ឌុច** ក៏មានចេតនាមិនចង់ឆ្លើយតបនឹងសំណួរមួយចំនួន និងបានផ្តល់ការពន្យល់យ៉ាងវែងដែលមិនជាប់ពាក់ព័ន្ធនឹងសំណួរ។ ឧទាហរណ៍ នៅពេលដែល **ឌុច** បានកំពុងពន្យល់ពីភាពមិនស៊ីចង្វាក់នៅក្នុងសក្ខីកម្មរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ និងតុលាការយោធានោះ មេធាវី **វែកតែន** បានកាត់សម្តីគាត់ ដោយហេតុផលថា ចំពោះចម្លើយដែលមិនស៊ីចង្វាក់គ្នា គឺគាត់ចង់ឲ្យ **ឌុច** ធ្វើការគូសបញ្ជាក់តែទំនាក់ទំនងរបស់ **ប៉ង់** ដោយមិនសំដៅលើបុគ្គលផ្សេងនៅក្នុងកំណត់ហេតុនេះទេ។ ប្រធានអង្គជំនុំជម្រះ បានប្រាប់ទៅមេធាវី **វែកតែន** ថា **ឌុច** កំពុងតែពន្យល់ និងដកស្រង់សម្តីពីកថាខណ្ឌដែលមានជាប់ពាក់ព័ន្ធនឹង **ប៉ង់** ដូច្នេះ គាត់មានសិទ្ធិក្នុងការបញ្ជាក់ឲ្យកាន់តែច្បាស់ ទោះបីជាពាក់ព័ន្ធនឹងបុគ្គលផ្សេង។ មេធាវី **វែកតែន** បាន

ជំទាស់ថា គាត់ចង់ឲ្យ **ឌុច** ពន្យល់តែទៅលើចម្លើយដែលមិនស៊ីចង្វាក់ដែលគាត់លើកបង្ហាញតែប៉ុណ្ណោះ ព្រោះព័ត៌មានផ្សេងទៀត **ឌុច** បានលើករួចហើយ។

តបតាមសំណើរបស់ **ឌុច** អង្គជំនុំជម្រះបានណែនាំមេធាវី ***វែកគែន*** ឲ្យដកឯកសារពីសាក្សី ប្រសិនបើគាត់ចង់ពិភាក្សាតែទៅលើ **ប៉ង់** ព្រោះថា ឯកសារនេះបាននិយាយសំដៅដល់បុគ្គលពីរនាក់ទៀត។ គួរឲ្យចាប់អារម្មណ៍នោះ លោកប្រធាន **និល ណុន** បានគាំទ្រចំពោះហេតុផលរបស់ **ឌុច** ហើយបានថ្លែងទៅកាន់មេធាវី ***វែកគែន*** ឲ្យដកឯកសារចេញ។ មេធាវី ***កាណាវ៉ាស*** បានជំទាស់នឹងការសម្រេចនេះ ដោយលើកឡើងថា មេធាវី ***វែកគែន*** កំពុងព្យាយាមបង្ហាញដល់អង្គសវនាការថា **ឌុច** កំពុងនិយាយកុហក។ មេធាវី ***កាណាវ៉ាស*** បន្តថា ការបដិសេធចំពោះការលើកឡើងរបស់ក្រុមមេធាវីការពារក្តី គឺមិនមែនជារឿងធម្មតាទេ។ លោកមេធាវីស្នើថា **ឌុច** គួរតែឆ្លើយតបនឹងសំណួរទាំងនេះ និងមិនគួរមានសិទ្ធិលើការចាត់ចែងការគ្រប់គ្រងកិច្ចដំណើរការរបស់អង្គជំនុំជម្រះឡើយ។

ប្រហែលជាពីរទៅបីករណី ដែល **ឌុច** បានព្យាយាមបង្វែរការឆ្លើយសំណួរទៅជាការពិភាក្សា ឬមិនឆ្លើយតបទៅនឹងសំណួរ។ ចំណុចនេះកើតឡើង នៅពេលមេធាវី ***កាណាវ៉ាស*** បានសួរសំណួរមួយ ហើយ **ឌុច** បានប្រាប់ទៅអង្គជំនុំជម្រះថា គាត់ចង់ងាកទៅឆ្លើយពីសំណួរមុនសិន។ នៅពេលអង្គជំនុំជម្រះយល់ព្រមនឹងសំណើរបស់ **ឌុច** ឲ្យគាត់បន្តវេទិកា ពេលនោះមេធាវី ***កាណាវ៉ាស*** ក៏បានកាត់សម្តីសាក្សី ហើយលើកឡើងថា សាក្សីមិនអាច "ធ្វើតាមតែអំពើចិត្តនោះទេ ឬលើកបង្ហាញឯកសារដែលគាត់ចង់ថ្លែង"។[28] ដូច្នេះ ដើម្បីជាការសម្របសម្រួល លោកប្រធាន **និល ណុន** បានបង្គាប់ឲ្យ **ឌុច** ទុកឯកសារ និងការពិភាក្សានោះមួយអន្លើសិន ហើយបង្គាប់ឲ្យឆ្លើយតបនឹងសំណួរដែលបានសួរ។

នាសប្តាហ៍នេះ ការពិភាក្សាសួរដេញដោល **ឌុច** បានធ្វើឲ្យលេចចេញនូវករណីជាច្រើន ជាពិសេសចម្លើយដែលថា គាត់យល់ដឹងពីរបបកម្ពុជាប្រជាធិបតេយ្យនៅដំណាក់កាលចៅក្រមស៊ើបអង្កេត ឬនៅចំពោះមុខអង្គជំនុំជម្រះ។ ក៏ប៉ុន្តែ ការយល់ដឹងតាមរយៈការអានសៀវភៅ តាមរយៈហេតុការណ៍ ឬតាមបទពិសោធន៍របស់គាត់ គឺនៅមិនទាន់ច្បាស់ និងបែងចែកដាច់នៅឡើយ។

## ផ្នែកទី៣ ៖ បញ្ហាច្បាប់ និងនីតិវិធី

ពេញមួយសប្តាហ៍នេះ ភាគីនានាបានលើកឡើងពីបញ្ហាសំណួរនាំមុខជាច្រើនដង ទោះបីជា អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចថា សំណួរនាំមុខមិនអនុញ្ញាតឲ្យសួរដេញដោលក៏ដោយ។ ក្រៅពីនេះ បញ្ហានៃការលើកបង្ហាញឯកសារ ក៏អង្គជំនុំជម្រះបានធ្វើការណែនាំ "គួរឲ្យមានការប្រយ័ត្នប្រយែងខ្ពស់" ជាពិសេសឯកសារនៅក្នុងដីកាដំណោះស្រាយ។ បញ្ហាផ្សេងទៀត គឺការហាមឃាត់មិនឲ្យប្រើប្រាស់ចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម ធ្វើជាព័ត៌មានគោល។

### ក. សំណួរនាំមុខ និងសំណួរបើក

នៅក្នុងអំឡុងកិច្ចពិភាក្សាដេញដោល **ឌុច** ដោយក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** មេធាវី ***កាណាវ៉ាស*** បានកាត់សម្តី **ឌុច** និងបានធ្វើការណែនាំយ៉ាងម៉ឺងម៉ាត់ឲ្យ **ឌុច** ឆ្លើយចម្លើយខ្លីៗ "បាទ"

ឬក៏ “ទេ”។ ភ្លាមៗនោះ លោកស្រីចៅក្រម **ខាតរ៉ាយថ៍** (Cartwright) បានធ្វើអន្តរាគមន៍ និងបានបញ្ជាក់ថា ភាគីទាំងអស់ “មិនអាចឲ្យសាក្សីឆ្លើយត្រឹមតែ ‘បាទ’ ឬក៏ ‘ទេ’ នោះទេ”។[29] ភាគីអាចដាក់សំណួរជាក់លាក់ ដែលអាចឲ្យសាក្សីឆ្លើយ “បាទ” ឬក៏ “ទេ” ក៏ប៉ុន្តែ សាក្សីមានសិទ្ធិឆ្លើយតាមការយល់ឃើញរបស់ខ្លួន។ ចៅក្រម **ខាតរ៉ាយថ៍** ក្រើនរម្លឹកដល់ភាគីថា សំណួរនាំមុខមិនត្រូវបានអនុញ្ញាតឲ្យសួរនោះទេ។ មេធាវី **កាណាវ៉ាស** បានជំទាស់ និងលើកឡើងថា យោងតាមកិច្ចពិភាក្សានៅក្នុងកិច្ចប្រជុំជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់នៃសាលាដំបូងថា ៖

> *ដោយគោរព យើងបានជួបអ្នកស្រី **សូសាន ឡាម** (Susan Lamb) ដែលជាមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង។ អ្នកស្រីបានប្រាប់ពួកយើងថា ភាគីដែលបានកំពុងសួរដេញដោលសាក្សី មិនមែនជាភាគីដឹកមុខសាក្សីនោះទេ ហើយទទួលបានសិទ្ធិក្នុងការសួរសំណួរនាំមុខ។ នេះគឺជាអ្វីដែលពួកយើងត្រូវបានគេប្រាប់។*[30]

ទោះបីជាយ៉ាងណា មេធាវី **កាណាវ៉ាស** បានអះអាងថា គាត់គោរពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ។ គាត់ក៏បានគូសបញ្ជាក់ថា ដំបូងឡើយ គាត់បានស្នើសុំពេលវេលា ពីរថ្ងៃ ក្នុងការសួរដេញដោល **ឌុច** ក៏ប៉ុន្តែអង្គជំនុំជម្រះសម្រេចអនុញ្ញាតតែមួយថ្ងៃ ដូច្នេះ គាត់ព្យាយាមកាត់បន្ថយការតាំងសំណួរបើក ព្រោះវាចំណាយពេល។ លោកស្រីចៅក្រម **ខាតរ៉ាយថ៍** (Catwright) បានរម្លឹកមេធាវី **កាណាវ៉ាស** ថា **អ.វ.ត.ក** គឺគោរពទៅតាមប្រព័ន្ធផ្សេង សំណួររបស់ភាគីគឺត្រូវឆ្លងកាត់អង្គជំនុំជម្រះមុនទៅសាក្សី។

ភ្លាមៗនោះ សហព្រះរាជអាជ្ញាអន្តរជាតិ **វីល្លៀម ស្មីត** (Mr. William Smith) បានជំទាស់នឹងសំណួររបស់មេធាវី **កាណាវ៉ាស** ដោយថ្លែងថា ៖

> *ចៅក្រម **ខាតរ៉ាយថ៍** បញ្ជាក់ហើយថា សំណួរនាំមុខមិនអាចសួរបានទេ សំណួរគួរតែមានលក្ខណៈងាយៗ និងជាសំណួរបើក។ មេធាវីគួរតែសួរថា តើលោកធ្លាប់ទៅធ្វើទស្សនកិច្ចនៅទីស្នាក់ការរបស់ **អៀង សារី** ដែរឬទេ?*[31]

បន្ទាប់មក ព្រះរាជអាជ្ញា **ស្មីត** បានផ្តល់មូលហេតុថា សំណួរទាំងនោះ ជាសំណួរនាំមុខ ដែលដឹកមុខសាក្សីឲ្យប្រើប្រាស់ឧបមាវិធី នាំឲ្យមានការភាន់ច្រឡំជាអាទិ៍។ យោងតាមពេលវេលាមានកំណត់ មេធាវី **កាណាវ៉ាស** បានបន្តការសួរដេញដោលរបស់ខ្លួន ដោយមិនរង់ចាំអង្គជំនុំជម្រះធ្វើការសម្រេចលើការជំទាស់របស់សហព្រះរាជអាជ្ញាឡើយ។ លោក **កាណាវ៉ាស** បាននិយាយថា “ខ្ញុំសូមបន្ត ខ្ញុំដឹងអំពីពេលវេលាមានតម្លៃ ហើយខ្ញុំយល់”។[32] មេធាវី **កាណាវ៉ាស** បានថ្លែងថា “ការព្រមានដោយយុត្តិធម៌”[33] ៖

> *លោកប្រធាន ខ្ញុំដឹងអំពីពេលវេលា ហើយខ្ញុំយល់។ ហើយខ្ញុំមិនចង់ឲ្យសហព្រះរាជអាជ្ញាគាត់កាត់សម្តីរបស់ខ្ញុំដូចដែលគាត់ធ្វើនៅក្នុងថ្ងៃនេះទេ។*[34]

## ខ. ការសន្និដ្ឋាន និងការដកស្រង់សម្តីនៅក្នុងឯកសារ

នៅពេលមេធាវី **កាណាវ៉ាស** បានលើកបង្ហាញ **ឌុច** ពីសម្រង់ដីកាដំណោះស្រាយ ដែលកំណត់ថា គាត់បានដឹងពីឋានានុក្រមថ្នាក់លើផ្ទាល់របស់គាត់ ក៏ប៉ុន្តែគាត់មិនបានដឹងព័ត៌មានលម្អិតពីដំណើរការនៃការសម្រេចចាប់ខ្លួនមនុស្ស។ ភ្លាមៗនោះ ព្រះរាជអាជ្ញា **ស្មីត** បានធ្វើការជំទាស់ ដោយឈរលើមូលដ្ឋានពីរ គឺ ៖ (១) សាក្សីកំពុងត្រូវបានឲ្យផ្តល់មតិយោបល់លើការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត[35] និង (២) មេធាវី **កាណាវ៉ាស** បានជ្រើសយកព័ត៌មានតែមួយផ្នែកសំខាន់ដើម្បីប្រយោជន៍របស់ខ្លួន។ ព្រះរាជអាជ្ញា **ស្មីត** បានគូសបញ្ជាក់ថា ការដកស្រង់នេះ គឺជាដកស្រង់យកតែព័ត៌មានមួយភាគនៃយោបល់ទាំងមូល ដែលចម្លើយទាំងស្រុងលើកឡើងថា តាមរយៈបទពិសោធន៍របស់ **ឌុច** នៅមន្ទីរស-២១ "**ឌុច** អាចមានលទ្ធភាពធ្វើការសន្និដ្ឋានចំពោះផែនការដាក់ចុះ និង សេចក្តីសម្រេចរបស់គណៈមជ្ឈិមពាក់ព័ន្ធនឹងការងារក្នុងជួរ និងក្រៅជួរ។"[36] ព្រះរាជអាជ្ញា **ស្មីត** បានបន្ថែមថា មេធាវី **កាណាវ៉ាស** គួរតែលើកបង្ហាញពីព័ត៌មានទាំងមូល ពីព្រោះការដកស្រង់តែមួយផ្នែកនៃមតិយោបល់ អាចនាំឲ្យមានការភាន់ច្រឡំ និងនាំមុខសាក្សី។

អង្គជំនុំជម្រះ បានសម្រេចតាមការជំទាស់របស់សហព្រះរាជអាជ្ញា ក្រោមមូលដ្ឋានថា មេធាវីការពារក្តីមិនបានដកស្រង់ព័ត៌មានទាំងមូល។ បន្ថែមលើនេះ អង្គជំនុំជម្រះបានសម្រេចថា ការសួរដេញដោលសាក្សីមិនគួរទាមទារឲ្យសាក្សីធ្វើការសន្និដ្ឋានលើដីកាដំណោះស្រាយឡើយ។

## គ. ចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម

បញ្ហានៃការប្រើប្រាស់ឯកសារដែលបានមកពីការធ្វើទារុណកម្ម ត្រូវបានយកមកពិភាក្សាជាថ្មីម្តងទៀតនៅក្នុងសវនាការនាថ្ងៃអង្គារនេះ។ ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** បានសួរដេញដោលសាក្សី ថាតើមានចម្លើយសារភាពណាមួយដែលបានឆ្លើយដាក់ **ប៉ង់** ដែរឬទេ។ ភ្លាមៗនោះ អង្គជំនុំជម្រះសាលាដំបូង បានធ្វើអន្តរាគមន៍ និងបានណែនាំមេធាវីឲ្យជៀសវាងការសួរសំណួរពាក់ព័ន្ធនឹងចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម។ មេធាវី **វ៉ែកតែន** បានបញ្ជាក់ថា គាត់មិនបានព្យាយាមប្រើប្រាស់ព័ត៌មានដែលបានមកពីការធ្វើទារុណកម្មនោះទេ។ បន្ទាប់មក អង្គជំនុំជម្រះក៏អនុញ្ញាតឲ្យមេធាវី **វ៉ែកតែន** បន្តប្រើប្រាស់វិធីសាស្ត្រសួរដេញដោលរបស់គាត់ ក៏ប៉ុន្តែនៅតែក្រើនរម្លឹកថា សំណួរទាំងឡាយមិនត្រូវចេញពីមូលដ្ឋាននៃចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ឡើយ។

# ផ្នែកទី៤ ៖ ការគ្រប់គ្រងសវនាការ

កិច្ចដំណើរការសវនាការនាសប្តាហ៍នេះ បានប្រព្រឹត្តទៅតាមកាលវិភាគរបស់អង្គជំនុំជម្រះដែលបានគ្រោងទុក បើទោះបីជាមានជម្លោះពាក្យសម្តីពីសំណាក់មេធាវី និងសាក្សីខ្លះៗក៏ដោយ។ ផ្ទុយទៅវិញ មេធាវី **កាណាវ៉ាស** បានថ្លែងថា កិច្ចដំណើរការសវនាការ នៅថ្ងៃទី៩ ខែមេសា ថាជា "ការតតាំង" ទៅវិញ។[37] ក្រៅពីនេះ ការបកប្រែភាសាក៏នៅតែជាបញ្ហាចោទដែលរំខានដល់សវនាការនាសប្តាហ៍នេះ។ ជាសង្ខេប អង្គជំនុំជម្រះបានប្រឹងប្រែងដឹកនាំកិច្ចដំណើរការសវនាការប្រកបដោយប្រសិទ្ធភាព ដោយធ្វើឲ្យការប្រឈមរបស់ភាគីមានភាពធូរស្រាល និងដំណើរការទៅតាមការកំណត់។

## ក. ការគ្រប់គ្រងនៅក្នុងបន្ទប់សវនាការ

បន្ទាប់ពីប្រធានអង្គជំនុំជម្រះ បានណែនាំឲ្យមេធាវី **វែកតែន** ដកឯកសារដែលបង្ហាញដល់សាក្សីចេញ ប្រសិនបើគាត់មានបំណងសួរ **ឌុច** អំពីករណីរបស់ **ប៉ង់** ភ្លាមៗនោះ មេធាវី **កាណាវ៉ាស** បានធ្វើការជំទាស់ដោយការខឹងសម្បារចំពោះសេចក្តីសម្រេច និងលើកឡើងថា វាមិនមែនជាការត្រឹមត្រូវទេ ហើយបន្តថា សាក្សីមិនគួរអនុញ្ញាតឲ្យធ្វើជាអ្នកគ្រប់គ្រងលើកិច្ចដំណើរការសវនាការនោះឡើយ។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានបញ្ជាក់ថា តាមវិធានផ្ទៃក្នុង វិធាន ២២.៤ បានអនុញ្ញាតឲ្យមេធាវីធ្វើការថ្លឹះបញ្ជាំងស្វែងរកយុត្តិធម៌ និងជួយសម្រួលដល់ការប្រព្រឹត្តទៅរបស់សវនាការប្រកបដោយប្រសិទ្ធភាព ក៏ប៉ុន្តែ “ប្រសិនបើយើងធ្វើអ្វីដូចដែលមេធាវីការពារក្តី **អៀង សារី** លើកឡើង នោះដំណើរការសវនាការរបស់យើងនឹងមិនមានប្រសិទ្ធភាពនោះទេ”។[38]

## ខ. ការគ្រប់គ្រងពេលវេលា

មេធាវី **កាណាវ៉ាស** បានបញ្ចប់ការសួរដេញដោលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ទាំងការចោទការសួរសំណួរ និងការដាក់បង្ហាញឯកសារចំពោះសាក្សី ព្រោះក្រុមរបស់គាត់បានផ្តល់ឯកសារដល់ក្រឡាបញ្ជីជាមុន។ មេធាវី **កាណាវ៉ាស** បានលើកឡើងពីមូលដ្ឋាននៃការជំទាស់ជាច្រើន និងការមិនឆ្លើយតបនឹងសំណួរបានធ្វើឲ្យបាត់បង់ពេលវេលារបស់គាត់ជាច្រើន។ ក៏ប៉ុន្តែ នៅពេលមានចំណោទទាក់ទងនឹងសំណួរនាំមុខ មេធាវី **កាណាវ៉ាស** បានបកស្រាយថា ដោយសារតែពេលវេលាមានកំណត់ ដូច្នេះ គាត់បន្តការសួរដេញដោលដោយមិនរង់ចាំការសម្រេចពីអង្គជំនុំជម្រះ។ លោកមេធាវី ក៏បានគូសបញ្ជាក់ពីវិសមភាពចំពោះការបែងចែកពេលវេលារបស់ភាគី។ ពេលវេលាផ្តល់ដល់សហព្រះរាជអាជ្ញាជាង ប្រាំមួយថ្ងៃ ក្នុងការសួរដេញដោល ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលា មួយថ្ងៃ ចំណែកឯក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទទាំងបីក្រុមទទួលបានពេលវេលាសួរដេញដោល **ឌុច** តែ បួនថ្ងៃ ប៉ុណ្ណោះ។

ទោះបីជាយ៉ាងណា ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** បានបញ្ចប់ការសួរដេញដោលរបស់ខ្លួន ដោយប្រើប្រាស់ពេលវេលាតិចជាងមួយថ្ងៃ។ ចំណែកឯ ពេលវេលាដែលនៅសេសសល់ អង្គជំនុំជម្រះបានអនុញ្ញាតផ្តល់ឱកាសដល់ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **នួន ជា** ក្នុងការសួរសំណួរបន្ថែម។

## គ. វត្តមាន

ជនជាប់ចោទទាំងបីមានវត្តមានពេញមួយសប្តាហ៍នេះ។ ក៏ប៉ុន្តែ **អៀង សារី** បានស្នើសុំចូលរួមតាមដានសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំឃាំងខាងក្រោមនៃសាលសវនាការ បន្ទាប់ពីបញ្ចប់វគ្គពិភាក្សាទីមួយនាថ្ងៃនីមួយៗ។ ចំពោះ **នួន ជា** វិញ ក៏បានស្នើសុំផងដែរ បន្ទាប់ពីការបញ្ចប់វគ្គពិភាក្សាទីពីរ។ ចំណែកឯ **ខៀវ សំផន** មានវត្តមាននៅក្នុងបន្ទប់សវនាការពេញមួយសប្តាហ៍។

នៅកិច្ចដំណើរការសវនាការនាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ស្ថានភាពសុខភាពរបស់លោកចៅក្រម **ឡាវែន៍** (Lavergne) មានភាពល្អប្រសើរឡើងវិញ បន្ទាប់ពីមានបញ្ហាសុខភាពកាលពីសប្តាហ៍មុន។

**ការចូលរួមរបស់សាធារណជន** ៖ នៅថ្ងៃច័ន្ទ មានអ្នកទស្សនាប្រហែល ៣០០នាក់ មកពីស្រុកឈូក ខេត្តកំពត មកធ្វើការតាមដានកិច្ចដំណើរការសវនាការ។ នៅថ្ងៃអង្គារ សិស្សានុសិស្សជាច្រើនមានវត្តមាននៅក្នុងសាលសាធារណៈប្រមាណ ៥០០នាក់ ពីមកខេត្តព្រះវិហារ។

## ឃ. បញ្ហាបកប្រែភាសា និងបញ្ហាបច្ចេកទេស

នាសប្តាហ៍នេះ ប្រហែលជាពីរទៅបីលើកដែលចៅក្រមបានធ្វើការកត់សម្គាល់ និងបានប្រាប់អ្នកបកប្រែឲ្យមានការប្រុងប្រយ័ត្នចំពោះការបកប្រែភាសា។ បញ្ហាបច្ចេកទេសពាក់ព័ន្ធនឹងប្រព័ន្ធសំឡេងក៏កើតឡើងផងដែរ។ នៅថ្ងៃច័ន្ទ មេធាវី **កាណាវ៉ាស** បានថ្លែងថា "គេប្រាប់ខ្ញុំថា អត់មានការបកប្រែជាភាសាបារាំងទេ។ ដូច្នេះ ខ្ញុំសូមចោទសំណួរឡើងវិញដើម្បីទទួលបានការបកប្រែ។"[39] បន្ទាប់មក លោកប្រធាន **និល ណុន** ក៏បានធ្វើការកត់សម្គាល់អំពីកំហុសនៃការបកប្រែ និងបញ្ហាបច្ចេកទេសមួយចំនួន នៅពេលមេធាវី **កាណាវ៉ាស** បានសួរដេញដោល **ឌុច** ។ ចំណែកឯ សាក្សីក៏បានលើកបង្ហាញថា ការបកប្រែជាភាសាបារាំង ហាក់មិនមានភាពល្អប្រសើរទេ។ ដោយសារតែបញ្ហានេះ មេធាវី **កាណាវ៉ាស** បានអានសំណួរឡើងវិញ។

នៅសវនាការថ្ងៃអង្គារ ជាថ្មីម្តងទៀត **ឌុច** បានលើកឡើងថា ការបកប្រែជាភាសាបារាំងហាក់មិនមានភាពត្រឹមត្រូវ (**ឌុច** ស្តាប់ជាភាសាបារាំង)។ **ឌុច** បានបន្តថា ក្រុមមេធាវីការពារក្តីឲ្យជនជាប់ចោទ **ខៀវ សំផន** មិនគួរយកព័ត៌មានដែលមានការបកប្រែភាសាដោយមិនត្រឹមត្រូវនោះទេ។ ជាងនេះទៀត នៅពេលមេធាវី **វ៉េកគែន** កំពុងសួរដេញដោល **ឌុច** គាត់បានលើកឡើងថា គាត់មិនឮការបកប្រែជាភាសាបារាំងចំពោះចម្លើយរបស់សាក្សី។ លោកប្រធាន **និល ណុល** ក៏បានគូសបញ្ជាក់ពីការមិនមានការបកប្រែផ្សេងទៀត និងបានស្នើឲ្យមេធាវី **វ៉េកគែន** សួរសំណួរឲ្យបានច្បាស់ និងយឺតៗ ដើម្បីជាជំនួយដល់ការបកប្រែ។ ចុងបញ្ចប់នៃកិច្ចដំណើរការសវនាការនៅថ្ងៃដដែលនេះ លោកប្រធានបានណែនាំដល់ភាគីឲ្យរង់ចាំការបកប្រែបញ្ចប់សិនមុននឹងបន្តសួរសំណួរថ្មី និងធ្វើការសន្និដ្ឋានរបស់ខ្លួន។ នាសប្តាហ៍នេះ អង្គជំនុំជម្រះក៏បានស្នើឲ្យសាក្សី ឬមេធាវីដែលសួរដេញដោល និយាយឡើងវិញ ដោយសារតែមិនមានការបកប្រែជាភាសាខ្មែរ។

## ង. តារាងពេលវេលា

| កាលបរិច្ឆេទ | ចាប់ផ្តើម | សម្រាកពេលព្រឹក | អាហារថ្ងៃត្រង់ | សម្រាកពេលរសៀល | ផ្អាកសវនាការ | រយៈពេលសវនាការសរុប |
|---|---|---|---|---|---|---|
| ថ្ងៃច័ន្ទ ០៩/០៤/១២ | ៩:០១ | ១០:៣៨-១០:៥៨ | ១២:០៧-១៣:៣១ | ១៤:៣៨-១៤:៥៨ | ១៦:១៧ | ៥ម៉ោង និង ១២នាទី |
| ថ្ងៃអង្គារ ១០/០៤/១២ | ៩:០០ | ១០:៣៩-១១:០២ | ១២:០៩-១៣:៣១ | ១៤:៣៩-១៥:០១ | ១៦:១៦ | ៥ម៉ោង និង ៩នាទី |
| *រយៈពេលសវនាការជាមធ្យម* | | | | *៥ម៉ោង និង ១១នាទី* | | |
| *រយៈពេលសវនាការសរុបក្នុងសប្តាហ៍នេះ* | | | | *១០ម៉ោង និង ២១នាទី* | | |
| *ចំនួនម៉ោង ថ្ងៃ និងសប្តាហ៍នៃសវនាការ* | | | | *២១៦ម៉ោង និង ១៦នាទី* | | |
| *រយៈពេលសវនាការចំនួន ៤៩ថ្ងៃ អំឡុងពេល ១៤សប្តាហ៍* | | | | | | |

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WAR CRIMES STUDIES CENTER
UNIVERSITY OF CALIFORNIA, BERKELEY

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of **KRT TRIAL MONITOR** was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes Kong, Princess B. Principe, Sovanna Sek, Kimsan Soy, Chayanich Thamparipattra, and Penelope Van Tuyl as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002

are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

[1] Trial Chamber. Transcript of Trial Day 50 (10 April 2012), Case No. 002/19-09-2007. E1/62.1. [hereinafter, 10 APRIL TRANSCRIPT]. Lines 24-25; 1-4. 89-90.

[2] The Supreme Court Chamber sentenced Duch to life imprisonment for having committed the following crimes: (i) crimes against humanity of persecution on political grounds, extermination (encompassing murder), enslavement imprisonment, torture and other inhumane acts; and (ii) Grave breaches of the Geneva Conventions of 1949, particularly, willful killing, torture and inhumane treatment, willfully causing great suffering or serious injury to body or health, willfully depriving a prisoner of war or civilian of the rights of fair and regular trial, and unlawful confinement of a civilian.

[3] Mr. Raoul Marc Jennar appeared in Case 001 as an expert witness. See AIJI Case 001 KRT Trial Monitor. Issue No. 21 (week ending 20 September 2009). See also Annex A to Issue No. 21. Available at < http://forum.eastwestcenter.org/Khmer-Rouge-Trials/ >
And <http://socrates.berkeley.edu/~warcrime/documents/KRT_monitoring_report_NO_21_week_20.pdf>, last accessed on 21 May 2012.

[4] Trial Chamber. Transcript of Trial Day 49 (9 April 2012), Case No. 002/19-09-2007. E1/61.1. [hereinafter, 9 APRIL TRANSCRIPT]. Lines 10-11. 7.

[5] 9 APRIL TRANSCRIPT. Lines 15-16. 14.

[6] Ibid at lines 21-23. 14.

[7] Ibid at line 13. 24.

[8] Ibid at lines 12-13. 28.

[9] Ibid at lines 7-8. 44.

[10] Ibid at lines 7-8. 45.

[11] Ibid at lines 23-25; 1-3. 45-46.

[12] Karnavas indicated that this statement was from the written record of Duch's interview before the OCIJ on 25 June 2008. 9 APRIL TRANSCRIPT. Lines 8-11. 48.

[13] Karnavas indicated that this statement was from the written record of Duch's interview before the OCIJ on 5 May 2008. 9 APRIL TRANSCRIPT. Lines 19-21. 49.

[14] Karnavas indicated that this statement was from the written record of Duch's interview before the OCIJ on 29 November 2007. 9 APRIL TRANSCRIPT. Lines 18-23. 62.

[15] 9 APRIL TRANSCRIPT. Lines 2-3. 72.

[16] Ibid at lines 6-7. 94.

[17] Ibid at line 11. 104.

[18] Trial Chamber. Transcript of Trial Day 50 (10 April 2012). E1/62.1. [hereinafter, 10 APRIL TRANSCRIPT]. Line 5. 14.

[19] 10 APRIL TRANSCRIPT. Lines 7-10. 18.

[20] Duch said, "When Pang was detained at S-21, I did not interrogate him. I even -- I did not even go and meet him." 9 APRIL TRANSCRIPT. Lines 12-13. 8.

[21] 10 APRIL TRANSCRIPT. Lines 20-21. 20.

[22] Ibid at lines 23-24. 35.

[23] Note however that, in his previous testimony before the Chamber, Duch said Nuon Chea reprimanded him and asked if he wanted Kheiu Samphan to get into trouble. Duch also intimated that Nuon Chea made a veiled threat by asking, "would you wish to go to be assigned to work at the embassy?" Working at the embassy or "beng sent as a diplomat" are alleged euphemisms for arrest and execution. See CASE 002 KRT TRIAL MONITOR Issue No. 16, Hearing on Evidence Week 11 (26-29). 9.

[24] Interestingly, Duch was neither asked nor did he explain why he attended a meeting chaired by Khieu Samphan when, being the Secretary of S-21, his superior at the time was Nuon Chea.

[25] Duch said, "When Pang was arrested, Brother Nuon asked Brother Vorn to meet me and he sent along with him a letter designating him to work with me." 10 APRIL TRANSCRIPT. Lines 17-19. 51.

[26] 10 APRIL TRANSCRIPT. Lines 16-19. 83.

[27] Ibid at lines 3-4. 90.

[28] 9 APRIL TRANSCRIPT. Lines 4-5. 37.

[29] Ibid at lines 3-4. 10.

[30] Ibid at lines 25; 1-4. 10-11.

[31] Ibid at lines 12-16. 13.

[32] Ibid at line 5. 25.

[33] Ibid at line 4. 25.

[34] Ibid at line 5-7. 25.

[35] This objection was sustained and the Trial Chamber directed Mr. Karnavas to rephrase the question so as Witness will not be required to give a subjective answer. The Trial Chamber reiterated this pronouncement whenit ruled on the OCP's objection that counsel Karnavas had "cherry-picked" statements in the Closing Order.

[36] 9 APRIL TRANSCRIPT. Lines 9-12. 55.

[37] Ibid at line 11-12. 118.

[38] Ibid at lines 13-16. 33.

[39] Ibid at lines 10-12. 2.